# លិខិតទី១ របស់គ្រីស្តទូតប៉ូល
# ផ្ញើជូនគ្រីស្តបរិស័ទនៅក្រុងថេស្សាឡូនិក

## ពាក្យលំនាំ

**ក្រុងថេស្សាឡូនិក៖** នៅជំនាន់គ្រីស្តទូតប៉ូល ក្រុងថេស្សាឡូនិកធំណាស់ មានប្រជាជនប្រមាណ ៣០០.០០០នាក់។ អ្នកក្រុងជាច្រើនប្រកបអាជីវកម្មធ្វើពាណិជ្ជកម្ម។ មានមនុស្សជាតិសាសន៍ជាច្រើនរស់នៅលាយឡំគ្នានៅក្រុងនោះ។

**គ្រីស្តបរិស័ទ៖** គ្រីស្តទូតប៉ូលមកក្រុងថេស្សាឡូនិក នៅពេលលោកបំពេញបេសកកម្មទី២ គឺនៅ គ.ស ៥០ (កក ១៧,១-១០)។ លោកប្រកាសដំណឹងល្អក្នុងធម្មសាលានៃជនជាតិយូដា ដោយមានជនជាតិដទៃដែលគោរពកោតខ្លាចព្រះជាម្ចាស់ចូលរួមជាមួយគេផង។ អ្នកខ្លះនាំគ្នាជឿលើព្រះយេស៊ូជាព្រះគ្រីស្ត។ ប៉ុន្តែជនជាតិយូដាខ្លះ នាំគ្នាប្រឆាំងរករឿងលោកប៉ូល និងគ្រីស្តបរិស័ទជាខ្លាំង។ គ្រីស្តបរិស័ទក៏នាំលោកប៉ូលឲ្យចាកចេញពីក្រុងនោះ ធ្វើដំណើរទាំងយប់ ទៅក្រុងបេរេ រួចទៅក្រុងអាថែនទៀត។

### លិខិតគ្រីស្តទូតប៉ូល ៖

នៅក្រុងអាថែននោះ គ្រីស្តទូតប៉ូលព្រួយបារម្ភអំពីគ្រីស្តបរិស័ទក្រុងថេស្សាឡូនិក លោកក៏ចាត់លោកធីម៉ូថេ ជាសហការីដ៏ជំនិត ឲ្យទៅសួរសុខទុក្ខគេ។ រីឯលោកនិងលោកស៊ីលវ៉ាន ជាសហការីម្នាក់ទៀត បន្តដំណើរទៅក្រុងកូរិនថូ។ កាលណាលោកធីម៉ូថេមកពីថេស្សាឡូនិកវិញ ទាំងនាំដំណឹងថា គ្រីស្តបរិស័ទកាន់ជាប់ជំនឿ គ្រីស្តទូតប៉ូលសរសេរលិខិតមួយច្បាប់ សម្តែងអំណរសប្បាយនិងសេចក្តីស្រឡាញ់របស់លោក ហើយលើកទឹកចិត្តគេទៀតផង។

លោកសរសេរលិខិតនេះ នៅ គ.ស.៥១ គឺជាកណ្ឌនៃគម្ពីរសម្ពន្ធមេត្រីថ្មីនិពន្ធមុនគេបង្អស់។

# លិខិតទី១ របស់គ្រីស្ដទូតប៉ូល
# ផ្ញើជូនគ្រីស្ដបរិស័ទនៅក្រុងថេស្សាឡូនិក

## សូមជម្រាបសួរ

[១]យើងខ្ញុំ ប៉ូល ស៊ីលវ៉ាន និងធីម៉ូថេ សូម
១ជម្រាបមកព្រះសហគមន៍* នៅក្រុងថេស្សា
ឡូនិក ដែលកើតមកដោយសារព្រះជាម្ចាស់ជា
ព្រះបិតា និងជាមួយព្រះអម្ចាស់យេស៊ូគ្រីស្ដ។
សូមព្រះអង្គប្រោសប្រណី និងប្រទានសេចក្ដី
សុខសាន្តដល់បងប្អូន។

## ពាក្យអរព្រះគុណ

[២]នៅពេលអធិដ្ឋាន យើងតែងតែនឹកគិត
ដល់បងប្អូនទាំងអស់ជាដរាប ហើយអរព្រះ
គុណព្រះជាម្ចាស់ ព្រោះតែបងប្អូនជានិច្ច។
[៣]យើងនឹកចាំអំពីជំនឿបងប្អូន ដែលនាំឲ្យបង
ប្អូនធ្វើសកម្មភាព អំពីសេចក្ដីស្រឡាញ់ ដែល
នាំឲ្យបងប្អូនធ្វើការនឿយហត់ និងអំពីសេចក្ដី
សង្ឃឹម ដែលនាំឲ្យបងប្អូនស៊ូទ្រាំ។ ជំនឿ
សេចក្ដីស្រឡាញ់ និងសេចក្ដីសង្ឃឹមដែលយើង
មាននៅចំពោះព្រះភក្ត្រព្រះជាម្ចាស់ ជាព្រះបិតា
របស់យើង គឺមកពីព្រះយេស៊ូ ជាអម្ចាស់នៃយើ
ង។ [៤]បងប្អូនជាទីស្រឡាញ់នៃព្រះអម្ចាស់!
យើងដឹងហើយថា ព្រះអង្គបានជ្រើសរើសបង
ប្អូន [៥]ដ្បិតដំណឹងល្អ*ដែលយើងបានជូនមក
បងប្អូននោះ មិនមែនមកត្រឹមតែដោយពាក្យ
សម្ដីប៉ុណ្ណោះទេ គឺមកដោយព្រះជាម្ចាស់
សម្ដែងឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ* និង
ដោយបងប្អូនទទួលផលយ៉ាងអស្ចារ្យថែមទៀត
ផង។ កាលយើងនៅជាមួយបងប្អូន បងប្អូន
ជ្រាបស្រាប់ហើយ អំពីរបៀបដែលយើងបាន
ប្រព្រឹត្តសម្រាប់ ជាប្រយោជន៍ដល់បងប្អូន
នោះ។ [៦]បងប្អូនបានយកតម្រាប់តាមយើងនិង
យកតម្រាប់តាមព្រះអម្ចាស់ គឺទោះបីបងប្អូន
ជួបប្រទះនឹងទុក្ខវេទនាធ្ងន់ធ្ងរយ៉ាងណាក៏ដោយ
ក៏បងប្អូនបានទទួលព្រះបន្ទូល ដោយមាន
អំណរមកពីព្រះវិញ្ញាណដ៏វិសុទ្ធដែរ។ [៧]ហេតុ
នេះ បងប្អូនបានទៅជាគំរូដល់អ្នកជឿទាំងអស់
នៅស្រុកម៉ាសេដូននិងស្រុកអាខៃ [៨]ដ្បិតព្រះ
បន្ទូលរបស់ព្រះអម្ចាស់ ដែលចេញពីបងប្អូនទៅ
នោះ មិនត្រឹមតែលាន់ឮសុសសាយក្នុងស្រុកម៉ា
សេដូននិងស្រុកអាខៃប៉ុណ្ណោះទេ គឺជំនឿរបស់
បងប្អូនលើព្រះជាម្ចាស់ បានឮខ្ចរខ្ចាយទៅគ្រប់
ទីកន្លែង។ ដូច្នេះយើងមិនបាច់និយាយអ្វីទៀត
ឡើយ។ [៩]មនុស្សម្នារៀបរាប់អំពីរបៀបដែល
បងប្អូនទទួលយើង នៅពេលយើងមករកបង
ប្អូន និងអំពីរបៀបដែលបងប្អូនលះបង់ព្រះក្លែង
ក្លាយ បែរមករកព្រះជាម្ចាស់ដើម្បីគោរពបម្រើ
ព្រះអង្គដែលមានព្រះជន្មគង់នៅ និងជាព្រះដ៏
ពិតប្រាកដ។ [១០]បងប្អូនក៏ទន្ទឹងរង់ចាំព្រះបុត្រា
របស់ព្រះអង្គ យាងពីស្ថានបរមសុខ*មកគឺព្រះ
យេស៊ូ ដែលព្រះអង្គបានប្រោសឲ្យតើនឡើងពី
ចំណោមមនុស្សស្លាប់។ ព្រះយេស៊ូនេះហើយ
ដែលប្រោសយើងឲ្យរួចផុតពីការវិនិច្ឆ័យដែល

នឹងមក។

## គ្រីស្តទូតប៉ូលនៅក្រុងថេស្សាឡូនិក

១បងប្អូនជ្រាបស្រាប់ហើយថា យើងមករក
២បងប្អូន មិនមែនជាការឥតប្រយោជន៍ទេ ២គឺ
ដូចបងប្អូនជ្រាបស្រាប់ហើយ ក្រោយពេល
យើងបានរងទុក្ខលំបាក និងត្រូវគេជេរប្រមាថ
នៅក្រុងភីលីពនោះ មកព្រះជាម្ចាស់បាន
ប្រទានឲ្យយើងមានចិត្តអង់អាច ប្រកាស
ដំណឹងល្អ*របស់ព្រះអង្គដល់បងប្អូន ទោះបី
ត្រូវតយុទ្ធពុះពារខ្លាំង យ៉ាងណាក៏ដោយ។
៣សេចក្ដីដែលយើងទូន្មាន មិនមែនមកពីប្រែ
សេចក្ដីពិត ឬមានគោលបំណងមិនល្អ ឬមាន
កលល្បិចឡើយ។ ៤ផ្ទុយទៅវិញ មុននឹងផ្ញើ
ដំណឹងល្អមកយើង ព្រះជាម្ចាស់បានបន្សុទ្ធចិត្ត
យើងយ៉ាងណា យើងក៏ប្រកាសយ៉ាងនោះដែរ
យើងមិននិយាយដើម្បីផ្គាប់ចិត្តមនុស្សទេ គឺ
ដើម្បីឲ្យគាប់ព្រះហឫទ័យព្រះជាម្ចាស់ ដែល ប
ន្សុទ្ធចិត្តយើងនោះវិញ។

៥បងប្អូនជ្រាបហើយថា យើងមិនដែល
ពោលពាក្យបញ្ចើចបញ្ចើទាល់តែសោះ យើងក៏
មិនដែលធ្វើអ្វីដោយមានគំនិតលាក់លៀម ឬ
មានចិត្តលោភលន់ចង់បានប្រាក់ដែរ ដូចមាន
ព្រះជាម្ចាស់ជាសាក្សីស្រាប់។ ៦យើងពុំបាន
ស្វែងរកកិត្តិយស ដែលមកពីមនុស្សទេទោះបីពី
សំណាក់បងប្អូន ឬពីសំណាក់អ្នកឯទៀតៗក៏
ដោយ។ ៧ក្នុងឋានៈជាទូត*របស់ព្រះគ្រីស្ត ថ្វី
ដ្បិតតែ យើងមានសិទ្ធិបង្គាប់បញ្ជាបងប្អូនយ៉ាង
ណាក្ដី ក៏យើងរស់ក្នុងចំណោមបងប្អូន ដោយ
ស្លូតបូត ដូចមាតាបីបាច់ថែរក្សាកូនខ្ចីដែរ។
៨ដោយយើងជាប់ចិត្តស្រឡាញ់បងប្អូន ខ្លាំង
យ៉ាងនេះ យើងមិនត្រឹមតែមានបំណងប្រគល់
ដំណឹងល្អជូនបងប្អូនប៉ុណ្ណោះទេ គឺរហូតដល់
ទៅស៊ូប្ដូរជីវិតសម្រាប់បងប្អូន ថែមទៀតផង
ដ្បិតយើងស្រឡាញ់បងប្អូន ខ្លាំងណាស់!។
៩បងប្អូនពិតជានឹកចាំ នូវកិច្ចការដែលយើង
បានធ្វើទាំងនឿយហត់នោះមិនខានឡើយ គឺ
នៅពេល យើងប្រកាសដំណឹងល្អរបស់ព្រះជា
ម្ចាស់ដល់បងប្អូន យើងខំធ្វើការទាំងយប់ ទាំង
ថ្ងៃ ដើម្បីកុំឲ្យនរណាម្នាក់ក្នុងចំណោមបងប្អូន
ពិបាកនឹងផ្គត់ផ្គង់ដល់យើង។ ១០យើងបានរស់
នៅជាមួយបងប្អូនជាអ្នកជឿ ដោយឥរិយាបថដ៏
ល្អវិសុទ្ធ* សុចរិត* ឥតកំហុស យើងមានទាំង
បងប្អូននិងព្រះជាម្ចាស់ជាសាក្សីស្រាប់។ ១១បង
ប្អូនក៏ជ្រាបថា យើងបានប្រព្រឹត្តចំពោះបងប្អូន
ម្នាក់ៗ ដូចឪពុកប្រព្រឹត្តចំពោះកូនដែរ ១២គឺ
យើងបានទូន្មាន និងលើកទឹកចិត្តបងប្អូនហើយ
យើងក៏បានអង្វរបងប្អូន ឲ្យរស់នៅយ៉ាងសម
រម្យ ស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់
ដែលបានត្រាស់ហៅបងប្អូន ឲ្យមកចូលរួមក្នុង
ព្រះរាជ្យ* និងសិរីរុងរឿងរបស់ព្រះអង្គ។

១៣ហេតុនេះហើយ បានជាយើងតែងតែអរ
ព្រះគុណព្រះជាម្ចាស់ជានិច្ច ព្រោះនៅពេល
ដែលយើងនាំដំណឹងល្អ មកជូនបងប្អូនស្ដាប់
បងប្អូនបានទទួលយក ដោយពុំចាត់ទុកថាជា
ពាក្យសម្ដីរបស់មនុស្សទេ គឺបងប្អូនចាត់ទុក
ពាក្យសម្ដីរបស់ខ្ញុំនេះ ដូចជាព្រះបន្ទូលរបស់
ព្រះជាម្ចាស់។ តាមពិតជាព្រះបន្ទូលរបស់ព្រះ
អង្គមែន ហើយព្រះបន្ទូលនេះកំពុងតែបង្កើត

ផលក្នុងបងប្អូនជាអ្នកជឿ។ ១៤បងប្អូនក៏បាន
យកតម្រាប់ តាមព្រះសហគមន៍*របស់ព្រះជា
ម្ចាស់ នៅស្រុកយូដាដែលរួមក្នុងអង្គព្រះគ្រិស្ត
យេស៊ូនោះដែរ ដ្បិតបងប្អូនបានរងទុក្ខលំបាក
ដោយជនរួមជាតិរបស់បងប្អូនធ្វើបាប ដូចព្រះ
សហគមន៍នៅស្រុកយូដា ត្រូវជនជាតិយូដាធ្វើ
បាបដែរ។ ១៥ពួកគេបានធ្វើគុតព្រះអម្ចាស់
យេស៊ូ និងសម្លាប់ពួកព្យាការី*ព្រមទាំងធ្វើទុក្ខ
បុកម្នេញយើងទៀតផង។ អ្នកទាំងនោះ មិន
គាប់ព្រះហឫទ័យព្រះជាម្ចាស់ទេ ហើយគេក៏ជា
ខ្មាំងសត្រូវ នឹងមនុស្សលោកទាំងអស់! ១៦ពួក
គេបានរារាំងយើងមិនឲ្យប្រកាសដំណឹងល្អដល់
ជាតិសាសន៍ដទៃ ដើម្បីកុំឲ្យជាតិសាសន៍ទាំង
នោះទទួលការសង្គ្រោះ។ ធ្វើដូច្នេះអំពើបាប
របស់ពួកគេ ចេះតែកើនឡើងៗដល់កម្រិត
ហើយនៅទីបំផុត ព្រះជាម្ចាស់ទ្រង់ព្រះពិរោធ
ពួកគេ[ក]។

## គ្រិស្តទូតប៉ូលចង់ជួបគ្រិស្តបរិស័ទ

១៧ចំពោះយើងវិញ ទោះបីយើងនៅឆ្ងាយពី
បងប្អូនមួយគ្រាយ៉ាងណាក្ដី គឺយើងនៅឆ្ងាយតែ
រូបកាយប៉ុណ្ណោះ ឯចិត្តយើងនៅជាប់នឹងបងប្អូន
ជានិច្ច ហើយយើងខំប្រឹងប្រែងរកគ្រប់មធ្យោ
បាយ ដើម្បីឲ្យបានមកជួបបងប្អូន ព្រោះយើង
ចង់ឃើញមុខបងប្អូនខ្លាំងណាស់។ ១៨ហេតុនេះ
ហើយបានជាយើង គឺខ្ញុំប៉ូលផ្ទាល់បានរក
ឱកាស មកជួបមុខបងប្អូនពីរបីលើកហើយក៏
ប៉ុន្តែ មារ*សាតាំងចេះតែរារាំងដំណើរយើងជា
និច្ច។ ១៩បងប្អូនហ្នឹងហើយដែលធ្វើឲ្យយើង
មានសង្ឃឹម មានអំណរសប្បាយ និងមានទី
អាងនាំឲ្យយើងបានខ្ពស់មុខ នៅចំពោះព្រះភ
ក្ត្រព្រះអម្ចាស់យេស៊ូ នៅពេលព្រះអង្គយាងម
ក។ ក្រៅពីបងប្អូនគ្មានអ្នកឯណាទៀតឡើយ!
។

១ដោយ យើងពុំអាចទ្រាំតទៅទៀតបាន
៣យើងក៏សម្រេចចិត្តស្នាក់នៅក្រុងអាថែនតែ
គ្នាយើង ២ហើយចាត់លោកធីម៉ូថេជាបងប្អូន
របស់យើង ដែលធ្វើការរួមជាមួយព្រះជាម្ចាស់
ក្នុងការប្រកាសដំណឹងល្អ*របស់ព្រះគ្រិស្ត ឲ្យ
មកជួយពង្រឹង និងដាស់តឿនបងប្អូនឲ្យមាន
ជំនឿរឹងប៉ឹងឡើង ៣ដើម្បីកុំឲ្យមាននរណាម្នាក់
ធ្លាក់ទឹកចិត្ត ព្រោះតែទុក្ខវេទនាដែលកំពុងកើត
មាននៅពេលនេះ។ បងប្អូនជ្រាបស្រាប់ហើយ
ថា ព្រះជាម្ចាស់បានតម្រូវឲ្យយើងជួបប្រទះ
នឹងទុក្ខវេទនាយ៉ាងនេះឯង។ ៤កាលយើងនៅ
ជាមួយបងប្អូននៅឡើយ យើងបានជម្រាបបង
ប្អូនរួចហើយថា យើងមុខជានឹងជួបទុក្ខវេទនា។
ទុក្ខវេទនានេះក៏កើតមានមែនដូចបងប្អូនជ្រាប
ស្រាប់។ ៥ហេតុនេះដោយខ្ញុំពុំអាចទ្រាំតទៅ
ទៀតបាន ខ្ញុំក៏ចាត់លោកធីម៉ូថេឲ្យមកយក
ដំណឹងអំពីជំនឿរបស់បងប្អូន ព្រោះខ្ញុំខ្លាចក្រែង
លោមេល្បួង មកល្បួងបងប្អូនបានបណ្ដាលឲ្យ
ការនឿយហត់របស់យើងបែរទៅជាអសារបង់វិ
ញ។

៦ឥឡូវនេះ លោកធីម៉ូថេទើបនឹងវិលត្រឡប់
ទៅជួបយើងវិញ ហើយគាត់នាំដំណឹងល្អ អំពី
ជំនឿ និងអំពីសេចក្ដីស្រឡាញ់របស់បងប្អូន
មកប្រាប់យើង។ គាត់ប្រាប់យើងថា បងប្អូននៅ
នឹករឭកយើងជានិច្ច ហើយមានបំណងចង់ជួប

យើងវិញយ៉ាងខ្លាំង ដូចយើងចង់ជួបបងប្អូនដែ
រ។ ៧ហេតុនេះ ជំនឿរបស់បងប្អូនបានធ្វើឲ្យចិត្ត
យើងបែរជាធូរស្រាលវិញ ទោះបីយើងពិបាក
ចិត្តគ្រប់យ៉ាង និងមានទុក្ខវេទនាយ៉ាងណាក្ដី។
៨ដោយបងប្អូនស្ថិតនៅខ្ជាប់ខ្ជួនក្នុងអង្គព្រះ
អម្ចាស់ដូច្នេះ យើងដូចជាមានជីវិតរស់វិញដែ
រ។ ៩យើងពុំដឹងជារកពាក្យអ្វីមកថ្លែងអំណរព្រះ
គុណព្រះជាម្ចាស់ អំពីបងប្អូននោះឡើយ ព្រោះ
តែបងប្អូន ធ្វើឲ្យយើងមានអំណររីករាយនៅ
ចំពោះ ព្រះភក្ត្រព្រះជាម្ចាស់របស់យើង។
១០ ទាំងយប់ទាំងថ្ងៃ យើងទទូចសូមព្រះអង្គ
មេត្តាប្រោសឲ្យបានឃើញមុខបងប្អូន ព្រមទាំង
ប្រទានឲ្យជំនឿរបស់បងប្អូនបានពេញលក្ខណៈ
កុំបីមានចន្លោះត្រង់ណាឡើយ។

១១សូមព្រះជាម្ចាស់ ជាព្រះបិតារបស់យើង
និងព្រះយេស៊ូជាអម្ចាស់នៃយើង ទ្រង់រៀបចំផ្លូវ
ឲ្យយើងមករកបងប្អូន។ ១២សូមព្រះអម្ចាស់
ប្រទានឲ្យបងប្អូនបានពោរពេញ ដោយសេចក្ដី
ស្រឡាញ់ដល់គ្នាទៅវិញទៅមក និងស្រឡាញ់
មនុស្សទាំងអស់ កាន់តែខ្លាំងឡើងៗជាអនេក
ដូចយើងបានស្រឡាញ់បងប្អូនដែរ។ ១៣សូម
ព្រះអង្គប្រទាន ឲ្យចិត្តគំនិតរបស់បងប្អូនមាន
ជំហររឹងប៉ឹង ឲ្យបងប្អូនបានវិសុទ្ធឥតខ្ចោះ នៅ
ចំពោះព្រះភក្ត្រព្រះជាម្ចាស់ ជាព្រះបិតារបស់
យើង ក្នុងពេលព្រះយេស៊ូជាអម្ចាស់នៃយើង
យាងមក ជាមួយពពួកទេវទូតដ៏វិសុទ្ធរបស់ព្រះ
អង្គ!

## របៀបរស់នៅដែលគាប់ព្រះហឫទ័យ ព្រះជាម្ចាស់

១ចំពោះរឿងឯទៀតៗ បងប្អូនបានរៀនពី
៤យើងអំពីរបៀបរស់នៅ ដែលគាប់ព្រះ
ហឫទ័យព្រះជាម្ចាស់ ហើយក៏ប្រព្រឹត្តតាមទៀត
ផង។ ដូច្នេះ យើងសូមអង្វរ និងសូមដាស់តឿន
បងប្អូន ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូថា សូម
ឲ្យបងប្អូនបានប្រសើរលើសនេះទៅទៀត!
២បងប្អូនជ្រាបស្រាប់ហើយថា យើងបានទូ
ន្មានបងប្អូនអ្វីខ្លះ ក្នុងព្រះនាមព្រះអម្ចាស់យេ
ស៊ូ។ ៣ព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺឲ្យបង
ប្អូនបានវិសុទ្ធ* ឲ្យបងប្អូនចៀសវាងអំពើប្រាស
ចាកសីលធម៌។ ៤ម្នាក់ៗត្រូវចេះរួមរស់ជាមួយ
ភរិយា[ខ]របស់ខ្លួនដោយវិសុទ្ធ និងថ្លៃថ្នូរ ៥មិនប
ណ្ដោយខ្លួនទៅតាមចំណង់តណ្ហា ដូចសាសន៍
ដទៃ ដែលមិនស្គាល់ព្រះជាម្ចាស់នោះឡើយ។
៦មិនត្រូវឲ្យបងប្អូនណាម្នាក់ប្រព្រឹត្តអ្វីខុស
ចំពោះបងប្អូនឯទៀតៗ ឬរំលោភលើសិទ្ធិគេក្នុង
រឿងសីលធម៌នេះឡើយ ដ្បិតព្រះអម្ចាស់នឹង
ដាក់ទោសដល់អ្នកប្រព្រឹត្តអំពើទាំងនេះ ដូច
យើងបាននិយាយ និងបញ្ជាក់រួចជាស្រេចហើ
យ។ ៧ព្រះជាម្ចាស់ត្រាស់ហៅយើងមកមិនមែន
ឲ្យរស់នៅ ក្នុងអំពើថោកទាបតទៅទៀតឡើយ
គឺឲ្យយើងបានវិសុទ្ធវិញ។ ៨ដូច្នេះអ្នកណា
បដិសេធមិនទទួលដំបូន្មាននេះ មិនត្រឹមតែ
បដិសេធមិនទទួលមនុស្សប៉ុណ្ណោះទេ គឺបដិសេ
ធមិនទទួលព្រះជាម្ចាស់ ដែលបានប្រទានព្រះ
វិញ្ញាណដ៏វិសុទ្ធរបស់ព្រះអង្គ មកបងប្អូននោះ
តែម្ដង។

៩រីឯការរាប់អានគ្នាជាបងប្អូនវិញ យើងមិន

ចាំបាច់សរសេរមកទូន្មានបងប្អូនទេ ដ្បិតបង
ប្អូនបានរៀនពីព្រះជាម្ចាស់ ឲ្យចេះស្រឡាញ់គ្នា
ទៅវិញទៅមក ១០ដូចបងប្អូនបានស្រឡាញ់បង
ប្អូនទាំងអស់ នៅស្រុកម៉ាសេដូនទាំងមូល
ស្រាប់ហើយ។ ក៏ប៉ុន្តែ យើងសូមដាស់តឿនបង
ប្អូនថា សូមតាំងចិត្តស្រឡាញ់ឲ្យបានកាន់តែ
ប្រសើរលើសនេះទៅទៀត!។ ១១ចូរយកចិត្ត
ទុកដាក់រស់នៅឲ្យបានស្រគត់ស្រគំ គិតតែពី
កិច្ចការខ្លួនឯង និងធ្វើការដោយកម្លាំងខ្លួនឯង
ផ្ទាល់ ដូចយើងបានផ្ដាំផ្ញើបងប្អូនរួចស្រេចហើ
យ។ ១២ធ្វើដូច្នេះ អ្នកដែលមិនមែនជាគ្រិស្ត
បរិស័ទនឹងគោរពបងប្អូន ហើយបងប្អូនក៏លែង
ត្រូវការឲ្យគេបម្រើទៀតដែរ។

## អំពីមនុស្សស្លាប់

១៣យើងចង់ឲ្យបងប្អូនជ្រាប[ក] អំពីអស់អ្នក
ដែលបានស្លាប់[ខ]ផុតទៅហើយ ដើម្បីកុំឲ្យបង
ប្អូនព្រួយចិត្តដូចអ្នកឯទៀតៗ ដែលគ្មានសេចក្ដី
សង្ឃឹមនោះឡើយ ១៤ប្រសិនបើ យើងជឿថា
ព្រះយេស៊ូពិតជាបានសោយទិវង្គត ហើយមាន
ព្រះជន្មថ្មីដ៏រុងរឿងមែន យើងក៏ត្រូវតែជឿថា
ព្រោះតែព្រះយេស៊ូ ព្រះជាម្ចាស់នឹងនាំបងប្អូន
ដែលបានស្លាប់ទៅហើយ ឲ្យបានរួមជាមួយព្រះ
យេស៊ូដែរ។ ១៥យើងសូមបញ្ជាក់ប្រាប់បងប្អូន
តាមព្រះបន្ទូលរបស់ព្រះអម្ចាស់ថា យើងដែល
មានជីវិតនៅឡើយ មិនទៅមុនអ្នកដែលស្លាប់
នោះទេ ១៦ដ្បិតនៅពេលមានស្នូរលាន់ឡើងជា
សញ្ញា ហើយនៅពេលឮសំឡេងអគ្គទេវទូត
និងសំឡេងត្រែរបស់ព្រះជាម្ចាស់ ព្រះអម្ចាស់
នឹងយាងចុះពីស្ថានបរមសុខមក។ អស់អ្នក
ស្លាប់ទៅ ដែលជឿលើព្រះគ្រិស្តនោះនឹងក្រោក
ឡើងជាមុន ១៧បន្ទាប់មក ទើបព្រះអម្ចាស់លើក
យើងដែលមានជីវិតនៅឡើយ ឲ្យឡើងទៅក្នុង
ពពក*ជាមួយអ្នកទាំងនោះ ដើម្បីទទួលព្រះ
អង្គក្នុងអាកាសវេហាស៍ ហើយយើងនឹងស្ថិត
នៅជាមួយព្រះអម្ចាស់ រហូតតទៅ។ ១៨ដូច្នេះ
សូមបងប្អូនយកពាក្យទាំងនេះមកដាស់តឿនគ្នា
ទៅវិញទៅមក។

៥ ១ចំពោះពេលវេលា និងពេលកំណត់នោះ
យើងមិនបាច់សរសេរមកប្រាប់បងប្អូនទេ ២
ដ្បិតបងប្អូនជ្រាបច្បាស់ហើយថា ថ្ងៃដែលព្រះ
អម្ចាស់យាងមក ប្រៀបបីដូចជាចោរចូលលួច
នៅពេលយប់។ ៣ពេលណាមនុស្សម្នាពោលថា
"សុខស្រួលហើយ! មានសន្តិសុខហើយ!"
ពេលនោះមហន្តរាយនឹងធ្លាក់លើគេមួយរំពេច
ពុំអាចគេចផុតបានឡើយគឺប្រៀបបីដូចជា ស្ត្រី
ឈឺផ្ទៃមុនសម្រាលកូនឈឺចុកចាប់ដែរ។ ៤រីឯ
បងប្អូនវិញ បងប្អូនមិនមែនស្ថិតនៅក្នុងភាព
ងងឹត បណ្ដោយឲ្យថ្ងៃនោះមកដល់ដោយមិន
ដឹងខ្លួនទេ ដូចជាពេលចោរចូលលួចនោះឡើ
យ។ ៥បងប្អូនទាំងអស់គ្នារស់នៅក្នុងពន្លឺ គឺរស់
នៅក្នុងពេលថ្ងៃ យើងមិនរស់នៅក្នុងយប់អន្ធ
ការ និងក្នុងភាពងងឹតទេ។ ៦ហេតុនេះ យើង
មិនត្រូវដេកលក់ដូចអ្នកឯទៀតៗឡើយ ផ្ទុយ
ទៅវិញ ត្រូវប្រុងស្មារតីហើយចេះប៉ាន់ប្រមាណ
ជានិច្ច។ ៧អស់អ្នកដែលដេកលក់តែងដេកលក់
នៅពេលយប់ ហើយអស់អ្នកស្រវឹងស្រា ក៏តែង
ស្រវឹងនៅពេលយប់ដែរ។ ៨រីឯយើងដែលរស់
នៅក្នុងពេលថ្ងៃវិញ យើងត្រូវតែចេះប៉ាន់

ប្រមាណដោយយកជំនឿ និងសេចក្ដីស្រឡាញ់
មកពាក់ធ្វើជាអាវក្រោះ ព្រមទាំងយកសេចក្ដី
សង្ឃឹមលើការសង្គ្រោះ មកពាក់ធ្វើជាមួកដែក
៩ ដ្បិតព្រះជាម្ចាស់មិនបានតម្រូវឲ្យយើងត្រូវ
ព្រះពិរោធឡើយ គឺព្រះអង្គឲ្យយើងទទួលការ
សង្គ្រោះ ដោយសារព្រះយេស៊ូគ្រីស្ដ ជាព្រះ
អម្ចាស់នៃយើង ១០សោយទិវង្គតសម្រាប់យើង
ដើម្បីឲ្យយើងរួមរស់ជាមួយព្រះអង្គ ទោះបី
យើងនៅរស់ក្ដី ស្លាប់ក្ដី[ច]។ ១១ដូច្នេះចូរ
ដាស់តឿនគ្នា និងអប់រំគ្នាទៅវិញទៅមកដូចបង
ប្អូនធ្លាប់ធ្វើស្រាប់។

## ពាក្យដាស់តឿនផ្សេងៗ

១២យើងសូមអង្វរបងប្អូន ឲ្យចេះគោរពអស់
អ្នកដែលធ្វើការនឿយហត់ ក្នុងចំណោមបងប្អូន
ជាអ្នកថែទាំបងប្អូនក្នុងមាគ៌ាព្រះអម្ចាស់ និង
ប្រៀនប្រដៅបងប្អូន។ ១៣ត្រូវលើកតម្លៃបងប្អូន
ទាំងនោះឲ្យបានខ្ពស់បំផុត ទាំងមានចិត្ត
ស្រឡាញ់ ដោយយល់ដល់កិច្ចការដែលគេ
បំពេញនោះផង។ ត្រូវរស់នៅឲ្យបានសុខសា
ន្ត។

១៤យើងសូមដាស់តឿនបងប្អូនថា ចូរប្រៀន
ប្រដៅអស់អ្នក ដែលរស់ដោយគ្មានសណ្ដាប់
ធ្នាប់ ចូរលើកទឹកចិត្តអស់អ្នកដែលគ្មានសេចក្ដី
ក្លាហាន ជួយទ្រទ្រង់អស់អ្នកទន់ខ្សោយ និង
មានចិត្តអត់ធ្មត់ចំពោះបងប្អូនទាំងអស់ផង។

១៥ចូរប្រយ័ត្ន កុំឲ្យនរណាម្នាក់ប្រព្រឹត្តអំពើ
អាក្រក់តបនឹងអំពើអាក្រក់ឡើយ តែត្រូវសង្វាត
ធ្វើអំពើល្អជានិច្ច គឺធ្វើចំពោះបងប្អូនគ្នាឯង និង
ចំពោះមនុស្សទូទៅ។

១៦ចូរមានអំណរសប្បាយជានិច្ច ១៧ចូរអធិ
ស្ឋានជាដរាប ១៨ចូរអរព្រះគុណព្រះជាម្ចាស់
គ្រប់កាលៈទេសៈទាំងអស់ ដ្បិតព្រះអង្គសព្វ
ព្រះហឫទ័យឲ្យបងប្អូន ដែលរួមជាមួយព្រះគ្រី
ស្ដយេស៊ូធ្វើដូច្នេះឯង។

១៩កុំរារាំងសកម្មភាព របស់ព្រះវិញ្ញាណ
ឡើយ[ឆ] ២០កុំមើលងាយការថ្លែងព្រះបន្ទូល
២១ ចូរពិចារណាមើល គ្រប់សេចក្ដីទាំងអស់
ហើយស្រង់យក នូវសេចក្ដីណាដែលល្អ។
២២ ត្រូវចៀសចេញឲ្យផុត ពីអំពើអាក្រក់គ្រប់
បែបយ៉ាង។

២៣ សូមព្រះជាម្ចាស់ជាប្រភពនៃសេចក្ដីសុខ
សាន្ដ ប្រោសបងប្អូនឲ្យបានវិសុទ្ធ*ទាំងស្រុង។
សូមព្រះអង្គថែរក្សាខ្លួនបងប្អូនទាំងមូល ទាំង
វិញ្ញាណ ទាំងព្រលឹង ទាំងរូបកាយ ឲ្យបាន
ស្អាត ឥតសៅហ្មង នៅថ្ងៃព្រះយេស៊ូគ្រីស្ដជា
អម្ចាស់នៃយើងយាងមក។ ២៤ព្រះអង្គដែលបាន
ត្រាស់ហៅបងប្អូនមក ទ្រង់មានព្រះហឫទ័យ
ស្មោះត្រង់ ព្រះអង្គនឹងសម្រេចការនេះជាពុំខា
ន។

២៥ សូមបងប្អូនអធិស្ឋាន*ឲ្យយើងផង។
២៦ សូមជម្រាបសួរបងប្អូនទាំងអស់ យ៉ាងស្និទ្ធ
ស្នាល។

២៧ ខ្ញុំសូមអង្វរបងប្អូនក្នុងព្រះនាមព្រះ
អម្ចាស់ថា សូមអានសំបុត្រនេះឲ្យបងប្អូនទាំង
អស់គ្នាស្ដាប់ផង។

២៨ សូមព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់នៃ

# យើង ប្រោសប្រណីដល់បងប្អូន!

ក. ឃ្លាដើម«នៅទីបំផុតព្រះពិរោធរបស់ព្រះជាម្ចាស់មកទាន់ពួកគេជាមិនខាន»។

ខ.ពាក្យដើម«ថូរបស់ខ្លួន»ដែលយើងអាចបកប្រែម៉្យាងទៀតថា«រូបកាយរបស់ខ្លួន»គឺម្នាក់ៗត្រូវចេះរក្សារូបកាយរបស់ខ្លួនນ່មានន័យថាចេះទប់ចិត្តចេះត្រួតត្រាលើរូបកាយខ្លួនឯង។•គ.ឃ្លាដើម«បងប្អូនអើយយើងមិនចង់ឲ្យបងប្អូននៅល្ងង់អំពីນ່»។•ឃ.ពាក្យដើម«អស់អ្នកដែលសំរាន្តលក់»។

ង. ឃ្លាដើម. «កូននៃពន្លឺ កូននៃថ្ងៃ»។•ច. ឃ្លាដើម«ទោះបីយើងប្រុងស្មារតីក្ដីឬដេកលក់ក្ដី»។

ឆ. ឃ្លាដើម«កុំពន្លត់ព្រះវិញ្ញាណ»។